**ទិដ្ឋាការចេញចូលមួយដង ឬច្រើន សម្រាប់ប្តី ប្រពន្ធ ឬកូនរបស់ជនជាតិជប៉ុនដែលស្នាក់នៅកម្ពុជា**

ប្រភេទទិដ្ឋាការនេះគឺសម្រាប់ សាមីជនបរទេសដែលជាប្តី ប្រពន្ធ ឬកូនស្របច្បាប់របស់ជនជាតិជប៉ុនដែលស្នាក់នៅកម្ពុជាជាមួយគ្នា មានទិដ្ឋាការស្នាក់នៅកម្ពុជារយៈពេលវែង និងកំពុងបម្រើការងារនៅកម្ពុជា។

- ទិដ្ឋាការចេញចូលម្តង៖ មានសុពលភាព៣ខែ និងអាចនៅជប៉ុនរហូតដល់៩០ថ្ងៃ (យោងតាមគម្រោងស្នាក់នៅជាក់ស្តែង)។
- ទិដ្ឋាការចេញចូលច្រើនដង៖ មានសុពលភាពរហូតដល់៣ឆ្នាំ (ស្នើលើកដំបូង បានរយៈពេល១ឆ្នាំ) និងម្តងអាចនៅជប៉ុនរហូតដល់៩០ថ្ងៃ។

អ្នកអាចទទួល ឬមិនទទួលបានទិដ្ឋាការនេះអាស្រ័យលើឯកសារដែលបានដាក់ស្នើ ដូចជាប្រវត្តិនៃការធ្វើដំណើរទៅប្រទេសជប៉ុន ស្ថានភាពអាពាហ៍ពិពាហ៍ ។ល។

| | | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|---|
| ឯកសារត្រូវរៀបចំដោយសាមីជន | | | |
| ១ | ☐ | លិខិតឆ្លងដែន ច្បាប់ដើម | ･មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>･ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ ច្បាប់ដើម<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | ･រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>･បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | ☐ | ឯកសារបញ្ជាក់ពីទំនាក់ទំនង | ･ឯកសារបញ្ជាក់អាស័យដ្ឋានបច្ចុប្បន្ន និងការរស់នៅជាមួយប្តីប្រពន្ធ ឬ ឪពុកម្តាយជនជាតិជប៉ុន។<br>ឧទាហរណ៍៖ ឯកសារដែលអាចបញ្ជាក់ឈ្មោះប្តីប្រពន្ធ ឬឪពុកម្តាយ និងអ្នកដាក់ពាក្យ មានដូចជាកិច្ចសន្យាជួលផ្ទះ ឬវិញ្ញាបនប័ត្របញ្ជាក់ទីលំនៅដែលធ្វើដោយអជ្ញាធរតំបន់។ល។ |
| ៤ | ☐ | លិខិតស្នើរសុំទិដ្ឋាការចេញចូលច្រើនដង<br>(មិនតម្រូវអោយដាក់សម្រាប់អ្នកមិនមានបំណងស្នើទិដ្ឋាការ | ･សរសេរពីមូលហេតុនៃការស្នើសុំទិដ្ឋាការចេញចូលច្រើនដង។<br>･ឯកសារបញ្ជាក់ពីប្រវត្តិធ្វើដំណើរចេញចូលជប៉ុន និងបច្ចុប្បន្នភាពរស់នៅជាមួយគ្នាក្នុងប្រទេសកម្ពុជាហើយ |

| | | | |
|---|---|---|---|
| | | ចេញចូលច្រើនដង) | រៀបការស្របច្បាប់ច្រើនជាងមួយឆ្នាំ។ |
| ឯកសារត្រូវរៀបចំដោយប្តីប្រពន្ធ ឬឪពុកម្តាយជនជាតិជប៉ុន (ច្បាប់ដើម ឬចម្លង) | | | |
| ៥ | ☐ | លិខិតឆ្លងដែនច្បាប់ចម្លង | · ទំព័រមានប្រវត្តិរូបផ្ទាល់ខ្លួន |
| ៦ | ☐ | ឯកសារបញ្ជាក់ការស្នាក់នៅរយៈពេលវែង | ត្រូវមានពចំនុចខាងក្រោម<br>☐ទិដ្ឋាការកម្ពុជា(ចេញចូលច្រើនដង)ស្នាក់នៅរយៈពេលវែង<br>☐ប័ណ្ណការងារចេញដោយក្រសួងការងារ<br>☐សេចក្តីចម្លងលិខិតឆ្លងដែនទំព័រមានត្រាអន្តោប្រវេសន៍ |
| ៧ | ☐ | លិខិតបញ្ជាក់ការចុះបញ្ជីគ្រួសារ(Kosekitohon) | · បញ្ជាក់ថ្មីៗក្នុងកំឡុងពេល៣ខែ |
| ឯកសារត្រូវរៀបចំដោយអ្នកចំណាយលើការស្នាក់នៅជប៉ុន (ច្បាប់ដើម ឬចម្លង) | | | |
| ៨ | ☐ | ឯកសារបញ្ជាក់ពីចំណូល | ត្រូវមានពចំនុចខាងក្រោម<br>☐លិខិតបញ្ជាក់ការងារ (បញ្ជាក់៖ មុខតំណែង រយៈពេលនៃការងារ ប្រាក់បៀវត្សរ៍។ល។)<br>ឬ ប៉ាតង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ (PATENT TAX) (សម្រាប់អ្នកធ្វើការអោយខ្លួនឯង)<br>☐សេចក្តីចម្លងតុល្យបញ្ជីគណនី Bank statements (ធ្វើបច្ចុប្បន្នភាពកំឡុងពេល៣ខែចុងក្រោយមកទល់នឹងថ្ងៃដាក់ពាក្យស្នើទិដ្ឋាការ) |